# ការប្រជុំពេញអង្គនៅ សេដាកតំបន់ ២

នៅថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០០៨ សេដាកតំបន់ ២ បានរៀបចំការ **ប្រជុំពេញអង្គ** របស់ខ្លួនលើកទីមួយក្នុងឆ្នាំ ២០០៨ ដែលមានរយៈពេល ១ ថ្ងៃ ។ ក្នុងកិច្ចប្រជុំនាពេលនោះ មានអ្នកចូលរួមសរុបចំនួនជាង ១០០ នាក់ មកពីខេត្តតាកែវ កំពត កំពង់ស្ពឺ និងខេត្តកណ្តាល ហើយអ្នកចូលរួមមានសមាសភាពមកពីបុគ្គលិកសេដាក ជំនួយការមូលដ្ឋាន (CFA) អ្នកដឹកនាំសហគមន៍វ័យក្មេង (YCL) និងអ្នកស្ម័គ្រចិត្តមកពីសាកលវិទ្យាល័យ វេទមហាឬស្សី ។ ការប្រជុំពេញអង្គត្រូវបានរៀបចំ ធ្វើឡើងក្នុងគោលបំណងដើម្បី :

- ធានាអោយបុគ្គលិក CFA and YCL ទាំងអស់ បានយល់ថែមទៀតអំពីការងារ សេដាក
- ធានាអោយបុគ្គលិក CFA and YCL ទាំងអស់បានដឹង និងយល់អំពីគំរោងដែលគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍មូលដ្ឋាននៅក្នុង សេដាកតំបន់ ២
- បង្កើននូវការសហការ និងសាមគ្គីភាពរវាង បុគ្គលិក និងបុគ្គលិក

បន្ទាប់ពីការជួបជុំ យើងបានសង្កេតឃើញ និងសំរេចបាននូវចំនុចសំខាន់ៗមួយចំនួនដូចខាងក្រោម :

- ការជួបជុំរបស់យើងបានប្រព្រឹត្តទៅប្រកបដោយភាពរលូន និងភាពសប្បាយរីករាយ
- អ្នកចូលរួមទាំងអស់បានដឹងអំពីការងារ សេដាក ឬ សេដាកបាននឹងកំពុងធ្វើអ្វីខ្លះ ជាពិសេសការងារ សេដាក នៅតំបន់ ២ ។ លើសពីនោះទៅទៀត បានដឹងអំពីរបៀបគាំទ្រ និងរបៀបធ្វើការជាមួយសហគមន៍កសិករ ទៅតាមប្រភេទគំរោងនីមួយៗដែលកំពុងមានសកម្មភាពនៅសេដាកតំបន់ ២ ដូចជា របៀបធ្វើការជាមួយកសិករសំរាប់គំរោងអភិវឌ្ឍន៍ចំរុះ (មានដូចជាគំរោងកាត់បន្ថយភាពក្រីក្រក្នុងចំណោមកសិករចិញ្ចឹមជីវិតដោយធ្វើស្រែតាមរយៈការជំរុញនូវប្រព័ន្ធចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (PRS) គំរោងបង្កើនការិតជីវភាពរស់នៅរបស់កសិករក្រីក្រ(ILFARM) គំរោងបណ្តុះបណ្តាលកសិករស្តីអំពី ប.វ.ស និងអង្គការកសិករ (FLIP) គំរោងសន្សំ គំរោងធ្វើការជាមួយក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធ (LAAR) គំរោងឡជីវៈឧស្ម័ន គំរោងផលិតផលសំគាល់ភូមិសាស្ត្រ(GI) គំរោងមតេយ្យសាលា (HCR) និងកម្មវិធីសន្សំរបស់បុគ្គលិក និងសហករឥណទាននៅ សេដាក តំបន់ ២ (ZCC) ។ល។

- បានជួយចូលរួមចំណែកនៅក្នុងការពង្រឹងស្មារតីក្រុម Team Spirits សំរាប់អ្នកធ្វើការជាមួយគ្នានៅក្នុងតំបន់ ២

ដោយឡែក សំរាប់ថ្ងៃខាងមុខ (២០០៨-២០០៩) សេដាកតំបន់ ២ មានផែនការរបស់ខ្លួនសំខាន់ៗ ដូចជា :



- ពង្រឹងនូវអ្វីដែលមានស្រាប់ ជាពិសេស កន្លែងសំរាប់រៀនសូត្រ អោយកាន់តែខ្លាំងថែមទៀត
- កែលំអនូវប្រព័ន្ធធ្វើការជាមួយ កម្រងសមាគមកសិករ (ជ្រើសរើសកសិករណាដែលមានសក្តានុពល ចងក្រងជាអង្គការមូលដ្ឋាន CBO)
- ពង្រឹងបន្ថែមទៀតនូវការងារក្រុមផលិតរបស់យើងនៅតាមមូលដ្ឋាន និងផ្សារណាត់
- រៀបចំអោយមានទីផ្សារកសិផលធម្មជាតិ(NAP) និងភោជនីយដ្ឋានបក្សីស្រុក(BS) នៅអង្គតាសោម
- ពង្រឹងសមត្ថភាពដល់បុគ្គលិក និង CFA អោយបានទៀងទាត់ ។